# ការសំភាសន៍របស់លោកពូ ម៉ៅ សារិះ

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍មាន ម៉ៅ សារិះ

<u>ការសង្ខេបប្រវត្តិរបស់លោកពូ ម៉ៅ សារិះ</u>

លោកពូ ម៉ៅ សារិះមានអាយុ56ឆ្នាំ នៅឆ្នាំ2018។លោកពូ ម៉ៅ សារិះ មានភេទប្រុស។លោកពូ ម៉ៅ សារិះ មានទីលំនៅបច្ចុប្បន្ននៅភូមិ5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ពូ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYUពូ ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូន ចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្ដាយ ហើយនឹងដូចតាចឹងនៅពេលដែរខ្ញុំសំភាសន៍ពូ ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះ www.cambodianoralhistories.byu.edu ចឹងហាសពូ ចឹងពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយ នេះទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ បាទយល់ព្រមដែរតើ!

កៈ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍នេះត្រូវបានធ្វើ នៅថ្ងៃទី10 ខែ2 ឆ្នាំ2018 ហើយការសំភាសន៍មួយនេះត្រូវបានធ្វើឡើងនៅភូមិទី5 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញពូ ចឹងសំរាប់ពូមានឈ្មោះពេញ ហៅឈ្មោះអីគេដែរពូ?

ខៈ ខ្ញុំមានឈ្មោះហៅថា ម៉ៅ សារិះ

កៈ ចុះមានឈ្មោះ ហៅក្រៅដែរទេពូ?

ខៈ ខ្ញុំមានឈ្មោះហៅក្រៅដែរនឹង ខ្លះគេហៅថា ពែក ខ្លះគេហៅថាសារិះនឹង

កៈ អូ!បាទពូ ចុះកាលពីក្មេងធ្លាប់មាននរណាហៅពូអីផ្សេងពីនឹងទៀតទេ?

ខ៖ កាលពីក្មេងនឹងហោស?

ក៖ កាលពីក្មេងធ្លាប់មានមិត្តភក្តិណាហៅឈ្មោះពូអីផ្សេងទៀតទេ?

ខ៖ អត់មានទេ

ក៖ ចឹងអត់មាននរណាហៅឈ្មោះអីទៀតទេណាពូ?

ខ៖ បាទអត់មានទេ មានតែឈ្មោះពីរនឹង

ក៖ ចុះសព្វថ្ងៃនឹងពូអាយុប៉ុន្មានដែរពូ?

ខ៖ ខ្ញុំអាយុ55ឆ្នាំហើយនឹង

ក៖ ពូសព្វថ្ងៃអាយុ55ឆ្នាំ ចុះពូកើតនៅថ្ងៃខែឆ្នាំណាដែរពូ?

ខ៖ ខ្ញុំកើតនៅឆ្នាំ1962

ក៖ ចុះខែវិញពូមានចងចាំទេពូ?

ខ៖ ខែខ្ញុំអត់បានចងចាំទេ

ក៖ ពូអាយុ56ឆ្នាំហើពូ?

ខ៖ ខ្ញុំអាយុ56ឆ្នាំហោស

ក៖ បាទពូឆ្នាំច័ន្ទគតិពូឆ្នាំអីគេដែរពូ លក្ខណះឆ្នាំជូត ឆ្លូវ ខាល ថោះហាសពូកើតនៅឆ្នាំអីគេដែរពូ?

ខ៖ ខ្ញុំកើតនៅឆ្នាំរោង

ក៖ ពូកើតនៅឆ្នាំរោងណាពូ ចុះពូកើតនៅភូមិអី ឃុំអី ស្រុកអី ខេត្តអីដែរពូ?

ខ៖ ខ្ញុំកើតនៅភូមិព្រៃរបើស

ក៖ ចុះឃុំវិញពូ?

ខ៖ នៅឃុំត្នោត ស្រុកកំពង់រ៉ូល

ក៖ នៅខេត្តស្វាយរៀង ?

ខ៖  បាទនៅខេត្តស្វាយរៀង

ក៖  ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូ?

ខ៖  ខ្ញុំមានបងប្អូនចំនួន4នាក់

ក៖  អូ!មានបងប្អូន4នាក់ណាពូ?

ខ៖  បាទប៉ុន្តែលាចាកលោកអស់ហើយនឹង

ក៖  ចឹងមានន័យថាសល់តែពូមួយទេ?

ខ៖  បាទៗនៅសល់តែពូមួយនឹងឯង

ក៖  អូ!ប៉ុន្តែមានស្រីប៉ុន្មាន ហើយនឹងប្រុសប៉ុន្មានដែរពូ?

ខ៖  មានស្រី2នាក់ នឹងប្រុស2នាក់

ក៖  ចឹងពូជាកូនទីប៉ុន្មានដែរពូ?

ខ៖  ពូជាកូនពៅគេតែម្តងនឹង

ក៖  អូ!ចឹងមានន័យថាបងៗរបស់ពូបានស្លាប់បាត់អស់ហើយ?

ខ៖  នឹងហើយគាត់ស្លាប់បាត់អស់ហើយនឹង

ក៖  ចុះគាត់ស្លាប់នៅពេលណាដែរពូ?

ខ៖  គាត់ស្លាប់នៅពេលស្រុកពិបាកវេទនាហាសគ្រូ

ក៖  ប៉ុន្តែនៅជំនាន់ណាដែរពូ នៅជំនាន់ពលពតហោសពូ?

ខ៖  នៅសម័យជំនាន់រដ្ឋកម្ពុជាយើងនឹង

ក៖  ចឹងមានន័យថាពេលដែរដាច់ពលពតណាពូ?

ខ៖  បាទនឹងផុតពីពលពតមកនឹង ដូចថាគាត់ឈឺដោយជំងឺហាស ដោយគ្មានប្រាក់កាក់មើលចឹង ហាសលោកគ្រូ

ក៖  អូ!ចឹងហោសពូមិនមែនស្លាប់ដោយសារអត់បាយទេ?

ខ៖  មិនមែនទេ ស្លាប់ដោយសារតែជំងឺតើ
បើពេលណុងមានពេទ្យដូចឥឡូវចឹងក៏វាមិនអីដែរ

ក៖  ត្រូវពួកគាត់នៅរស់ដល់ឥឡូវនឹងណាពូ?

ខ៖  នឹងហើយត្រូវគាត់មិនស្លាប់ទេនឹង

ក៖  ចុះបងៗរបស់ពូដែរពួកគាត់ស្លាប់នឹងពូអាចប្រាប់ឈ្មោះពួកគាត់បានទេពូ?

ខ៖  ប្រាប់បានតើ

ក៖  ពួកគាត់មានឈ្មោះអីគេដែរពូ?

ខ៖  ឈ្មោះម៉ៅ រិទ្ធិ

ក៖  នឹងបងគេណាពូ?

ខ៖  បាទនឹងបងគេបង្អស់ បន្ទាប់មកម៉ៅ ធី ហើយម៉ៅ ធឿន បន្ទាប់មកបានខ្ញុំ ម៉ៅ សារិះនឹង

ក៖  ចុះពូធ្លាប់មានចងចាំអនុស្សាវរីយ៍អីជាមួយបងៗរបស់ពូ កាលពីនៅក្មេងដែរទេពូ
ថាធ្លាប់ធ្វើអីជាមួយគ្នាចឹងពូ?

ខ៖  ចងចាំថាកាលពីជំនាន់ណុងគាត់រកស៊ីលក់តែអូស
វាយូរហើយកាលពីសម័យរដ្ឋកម្ពុជា

ក៖  អូ៎!ចឹងហោសពូ?

ខ៖  ជំនាន់ណុងនៅទួលស្លែង

ក៖  នៅទួលស្លែងហោសពូ?

ខ៖  នឹងហើយមានផ្ទះបាក់បែក យកឈើជាកង់ យកមកអារទៅលក់នៅច្បារអំពៅ
ជំនាន់ណុងវាចឹង ហើយគាត់ចេះតែគ្រាំគ្រាចឹង
ហើយថ្នាំពេទ្យពេលណុងវាមិនសូវគ្រប់គ្រាន់ទេមិនដូចឥឡូវនឹងទេ

ក៖  ចឹងមកពីគាត់មានជំងឺនេះនោះចឹងហោសពូ?

ខ៖ នឹងហើយវាឈឺទៅ ហើយគ្រាំគ្រាចឹងបានចឹងនឹង
ហើយធ្វើម៉េចគាត់ក៏បានលាចាកលោកដល់សព្វ ថ្ងៃនឹងទៅ

ក៖ ប៉ុន្តែពូមានចងចាំថាកាលពីនៅក្មេងពូធ្លាប់លេងអីជាមួយបងប្អូនរបស់ពូដែរទេ
ដូចជាធ្លាប់លេងឡឹកបាយឡ រឺមួយក៏លេងចុយអីចឹងពូ?

ខ៖ ប៉ុន្តែកាលពីជំនាន់ណុង កាលពីនៅតូចៗនឹង គាត់គ្មានស្អីទេ
គាត់មានតែបង្ហាត់បង្ហាញកុំអោយប្អូនៗ នឹងដើរលេងទៅផ្តេសផ្តាស់ចឹងទៅ

ក៖ ប៉ុន្តែអត់ដែរលេងអីទេ?

ខ៖ គាត់គ្រាន់តែដឹកនាំប្អូនៗនឹង ប៉ុន្តែគាត់នៅស្រែមិនមានអីទេគាត់រកស៊ីលក់ស្ពៃ
មានលក់ស្ពៃច្រូកចឹង ទៅនឹងហើយឪពុករបស់ខ្ញុំគាត់ជាអ្នកដាំដំណាំអីចឹងទៅ

ក៖ ចឹងមានន័យថាឪពុករបស់ពូមានស្រែចំការណពូ?

ខ៖ នៅស្រុកស្រែមានដាំដូចជា មានស្រែអំពក់សំរាប់ទុកដាំអីចឹងទៅ
ហើយបើអោយលឺបាយឡឹកបាយឡទេនឹង

ក៖ ប៉ុន្តែពូធ្លាប់ទៅស្រែចំការជាមួយបងប្អូនពូដែរ?

ខ៖ អត់ទេកាលណុងស្រុកកំណើតនៅណុង

ក៖ ចុពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ គាត់មានឈ្មោះ ម៉ៅ សុខ

ក៖ ប៉ុន្តែគាត់អាយុតឡូវប៉ុន្មានដែរពូ?

ខ៖ គាត់ស្លាប់បាត់យូរដែរហើយ បើគិតទៅវាតាំងពីឆ្នាំ1975

ក៖ ប៉ុន្តែគាត់ស្លាប់អស់ប៉ុន្មានឆ្នាំហើយ?

ខ៖ គាត់ជំនាន់សម្តេចតានឹង សម្តេចតាបងមួយឆ្នាំនឹង

ក៖ សម្តេចតាកើតនៅឆ្នាំ1920ជាងហីពូ?

ខ៖ បាទនឹងហើយជំនាន់សម្តេចតា

កៈ ចុះស្រុកកំណើតរបស់ពូ កើតនៅណាដែររបស់ឪពុកពូ?

ខៈ ឪពុករបស់ពូគាត់កើតនៅព្រៃរបើសនឹង ឃុំត្នោត ស្រុកកំពង់រ៉ូលនឹង

កៈ ចុះម្ដាយរបស់ពូមានឈ្មោះអីគេដែរ?

ខៈ ម្ដាយរបស់ពូមានឈ្មោះទេព ញឹប

កៈ ចុះគាត់នឹង ឪពុករបស់ពូនឹងបងគ្នាប៉ុន្មានឆ្នាំដែរពូ?

ខៈ ម្ដាយឆ្នាំរោង ហើយឪពុកឆ្នាំជូត

កៈ ចឹងមានន័យថាពួកគាត់បងគ្នា4ឆ្នាំហើយ?

ខៈ នឹងហើយបងគ្នា4ឆ្នាំនឹងហើយ

កៈ ប៉ុន្តែគាត់កើតនៅណាដែរនឹងពូ?

ខៈ គាត់កើតនៅណុងដែរនឹង

កៈ និយាយទាំងតា ទាំងយាយកើតនៅណុងទាំងអស់នឹងពូ?

ខៈ នឹងហើយកើតនៅភូមិព្រៃរបើសនឹងដូចគ្នានឹង

កៈ ហើយគាត់ក៏ឃើញគ្នានៅណុងទៅ?

ខៈ បាទហើយឃើញគ្នាទៅណាស់

កៈ ចុះឪពុករបស់ពូគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរពូ កាលគាត់នៅកំលោះនឹងកាលពីគាត់នៅក្មេង ចឹងហាសពូ?

ខៈ កាលនៅសម័យណុងគាត់ធ្វើស្រែចំការ គាត់ដាំដំណាំ

កៈ ប៉ុន្តែគាត់លក់ដូរដែរហោសពូ?

ខៈ បើនិយាយប្រវត្តិរបស់គាត់វិញនឹងកាលឆ្នាំ1941-1942នឹងគាត់ធ្វើជាទាហ៊ានបារាំង

កៈ អូ៎!ឪពុករបស់ពូគាត់ធ្វើជាទាហ៊ានហោសពូ?

ខ៖  បាទធ្វើជាទាហ៊ានដល់ពេលដែរមកស្រុកវិញចឹងទៅ គាត់ក៏ធ្វើស្រែចំការដូចតែគេដូចតែឯងចឹងទៅ ណាស់

ក៖  អូ៎!ចឹងគាត់ទៅធ្វើស្រែដែរ?

ខ៖  បើនិយាយអោយចំទៅគាត់ធ្វើជាទាហ៊ាននឹង

ក៖  ចឹងគាត់ធ្វើជាទាហ៊ានរហូតនឹងហោសពូ?

ខ៖  ពេលដែរគាត់ធ្វើជាទាហ៊ានបារាំងហើយ
គាត់ក៏បានធ្វើជាទាហ៊ានកងជីវពលរបស់សម្ដេចតាទៀតនឹង

ក៖  ចុះពូជំនាន់បារាំង នឹងជំនាន់អ៊ីសារ៉ាក់ជាមួយគ្នារឺក៏ខុសគ្នាដែរពូ?

ខ៖  ជំនាន់អ៊ីសារ៉ាក់នឹងជាមួយក្មួយ ដំណើរគ្នានឹង2វាប្រឆាំងគ្នានឹង
វាវៃគ្នាទៅវៃទាហ៊ានបារាំងហើយ ទាហ៊ានបារាំងវៃវិញ?

ក៖  ដូចជាជំនាន់បារាំងហើយ ជំនាន់ជប៉ុនមែនទេពូ?

ខ៖  និយាយទៅជំនាន់ណុងដំណើរគ្នាតែម្ដងនឹង

ក៖  និយាយរួមទៅជំនាន់សៃជានឹងជាជំនាន់ដែរគេបង្កើតសង្គ្រាមលោកមែនទេពូ?

ខ៖  នឹងជាសង្គ្រាមលោកលើកទី2នឹង
ដូចថាកាលពីជំនាន់ណុងឆ្នាំ1930ជាងហើយណាក្មួយ

ក៖  ជំនាន់1930ជាង ជាសង្គ្រាមលោកលើកទីមួយ
ហើយសង្គ្រាមលោកលើកទីនៅឆ្នាំ1945-1949មែនទេ ពូ?

ខ៖  ឆ្នាំ1930ជាង រហូតដល់ឆ្នាំ1942ជាសង្គ្រាមលោកលើទី2នឹង

ក៖  ចុះឪពុករបស់ពូគាត់កាចរឺមួយក៏គាត់ស្លូតដែរពូ?

ខ៖  ឪពុកពូមិនកាចទេគាត់ស្លូតដែរនឹង

ក៖  អូ៎!គាត់ស្លូតទេណពូ?

ខ៖  គាត់ស្លូត ហើយគាត់មានចិត្តមេត្តាធម

កៈ ចុះម្តាយរបស់ពូគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរពូ?

ខៈ គាត់មិនធ្វើអីទេ គាត់ជាមេផ្ទះ

កៈ អូ៎!គាត់ជាមេផ្ទះហោសពូ កាលពីគាត់មិនទាន់បានតា តើគាត់ធ្វើអីគេពូមានដឹងទេ?

ខៈ គាត់ធ្វើស្រែចំការដែរ

កៈ គាត់ធ្វើស្រែចំការជាមួយម៉ាក់ប៉ាគាត់ដែរហោសពូ?

ខៈ បាទនឹងហើយនៅជាមួយឪពុកគាត់ដែរនឹង

កៈ ចុះគាត់កាច រឺមួយក៏ស្លូតដែរពូ?

ខៈ គាត់ស្លូតនឹង

កៈ គាត់ស្លូតដែរហោសពូ?

ខៈ គាត់គ្មានទៅកាច អីទេនឹង ចាស់ជំនាន់ណុងគ្មានចេះកោងកាចអីទេ
បើថាឈ្លោះគ្នាវិញគ្មានបានយូរ ទេបន្តិចនឹងត្រូវគ្នាវិញហើយនឹង ចេះសុំទោសគ្នាហើយនឹង

កៈ មិនមែនដូចឥឡូវនឹងទេណាពូ?

ខៈ មិនមែនដូចយើងឥឡូវនឹងទេ យើងឥឡូវនឹងមិនបាច់ទេមានគុំនុំគុំគួនឥឡូវនឹងហើយ

កៈ ឥឡូវនឹងតែឈ្លោះគ្នាបន្តិចនឹងរត់ចេញពីផ្ទះរៀងខ្លួននឹងហើយ?

ខៈ បាទត្រូវហើយ មានការគុំគួនឥឡូវនឹងហើយ

កៈ ចុះពូមានចងចាំថាការពីពូនៅជាមួយពួកគាត់នឹង
ពូធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេពូ?

ខៈ មានតើលោកគ្រូ

កៈ មានអីគេខ្លះដែរទៅពូ?

ខៈ មានដូចថាគាត់ថ្លាប់ថៃយើងពីតូចក្រូចឆ្មាមក
ល្មមថៃរក្សាអោយយើងមានជីវិតធំដុំបានប៉ុណ្ណឹង ណាស់ក្មួយ

កៈ បាទពូបាទត្រូវហើយនឹង

ខ៖ ដល់ពេលចឹងគាត់ថែរក្សាយើងនឹង
បើនិយាយអោយចំទៅថាអ្វីៗក៏ដោយគាត់ជាអ្នកការពារយើង ទាំងអស់ចឹងទៅណាស់

ក៖ ត្រូវហើយពូ

ខ៖ លក្ខណៈថាការពារគ្រប់មធ្យោបាយដើម្បីយើងទាំងអស់គ្នានឹង
អើយយើងចេះតែនិយាយអោយ ឃើញទៅណាស់លោកគ្រូ
យើងទៅណាមកណាចឹងគាត់ចេះតែមិនអោយដើរផ្តេសផ្តាស់ចឹងទៅ

ក៖ បាទត្រូវហើយពូគាត់ខ្លាចយើងខូចមែនទេពូ?

ខ៖ មុននឹងដើរត្រូវប្រាប់គាត់

ក៖ យើងទៅណាមកណាត្រូវប្រាប់គាត់ទុកមុនមែនទេពូ?

ខ៖ បើថាដើរមិនប្រាប់គាត់ទេនោះមានរឿងហើយប្រយ័ត្នទៅ

ក៖ គាត់ស្លូតទេ ប៉ុន្តែបើគាត់កាច គឺកាចខ្លាំងតែម្តងនឹង?

ខ៖ បើមិនត្រូវគាត់កាចខ្លាំង ប៉ុន្តែគាត់កាចមិនដល់ថ្នាក់វៃទេ គ្រាន់តែសំលឹងមើលមុខនឹង

ក៖ គាត់គ្រាន់តែសំលឹងមុខកូនខ្លាចបាត់ហើយ មិនបាច់វៃទេមែនទេពូ?

ខ៖ នឹងហើយមិនបាច់វៃទេ

ក៖ កាលពីដើមនឹងគាត់សំលឹងតែមុខនឹងខ្លាចបាត់ទៅហើយមែនទេពូ?

ខ៖ បាទត្រូវហើយវាចឹង មិនបាច់ទៅវៃទេគ្រាន់តែសំលឹងតែមុខនឹងខ្លាច
ចេញញើសបាត់ទៅហើយនឹង បែកញើសជោកតែម្តងនឹង

ក៖ យាយតាខាងម្តាយរបស់ពូនឹង ពូមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ម្តាយរបស់ខ្ញុំហោស?

ក៖ យាយតាខាងម្តាយហាសពូស្គាល់ឈ្មោះកាត់ដែរទេ?

ខ៖ យាយតាខាងម្តាយ តាឈ្មោះតាទេព ហើយនឹងតាធើង

ក៖ ចុះយាយតាខាងឪពុកវិញពូ?

ខ៖ យាយតាខាងឪពុកឈ្មោះតាម៉ៅ

ក៖ ចុះយាយពូមានចងចាំឈ្មោះគាត់ដែរទេ?

ខ៖ យាយឈ្មោះយាយស្រី

ក៖ ឈ្មោះយាយ ស្រី ប៉ុន្តែពូមានចងចាំថាពួកគាត់អាយុប៉ុន្មានដែរទេពូ?

ខ៖ អូ!អត់ចងចាំទេមិនបានសួរគាត់ទេ

ក៖ គាត់អាយុច្រើនមែនទេពូ?

ខ៖ បាទៗនឹងហើយ

ក៖ ដោយសារតែជំនាន់ឪពុករបស់ពូអាយុចង់100ឆ្នាំបាត់ទៅហើយ ចុះទំរាំទៀតដឹងប៉ុន្មានទៅ?

ខ៖ នឹងហើយទំរាំយាយតាទៀតដឹងអាយុប៉ុន្មានទៅ

ក៖ ចុះពូមានដឹងថាយាយតាគាត់កើតនៅណាដែរពូមានដឹងទេ?

ខ៖ យាយតាគាត់កើតនៅនឹងដែរនឹង

ក៖ ទាំងខាងម្ដាយនឹងទាំងខាងឪពុកណាពូ?

ខ៖ នឹងទាំងខាងម្ដាយ នឹងទាំងខាងឪពុកនឹង

ក៖ ចុះក្រុមគ្រួសាររបស់ពូមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅពូ?

ខ៖ បើនិយាយប្រវត្តិទៅខ្ញុំមកនៅតាំងពីបែកអាពតមករហូតនឹង

ក៖ អូ! យូរដែរចឹងពូ?

ខ៖ នឹងហើយពេលដែរបែកអាពតនឹងបានខ្ញុំទៅធ្វើជាទាហ៊ានសម័យរដ្ឋកម្ពុជានឹង ដល់ពេលដែរធ្វើបាន អស់រយះពេល3ឆ្នាំនឹងបានខ្ញុំទៅស្រុកវិញនឹង ពេលទៅស្រុកទៅបានខ្ញុំជួបគ្រួសារខ្ញុំនេះនឹង

ក៖ អូ! ចឹងទេណាពូ?

ខ៖ អស់រយះពេល7ឆ្នាំបានខ្ញុំជួបគ្រួសារនៅណុងនឹង

កៈ ចឹងមានន័យថាពូមកនៅភ្នំពេញនឹងអស់រយៈពេលជិត40ឆ្នាំហើយណាពូ?

ខៈ បាទៗៗត្រូវហើយតាំងពីឆ្នាំ1979ណោះរហូតដល់ឥឡូវនឹង

កៈ ចុះពូមាននរណាគេនៅក្នុងក្រុមគ្រួសារពូទៅរស់នៅក្រៅប្រទេសទេពូ?

ខៈ អត់មានទេគ្រូអើយ

កៈ ចុះបងប្អូនក៏អត់មានដែរ?

ខៈ អត់មានទេនឹង

កៈ ចុះប្រពន្ធរបស់ពូនឹងគាត់ឈ្មោះអីគេដែរពូ?

ខៈ ប្រពន្ធរបស់ខ្ញុំនេះគាត់មានឈ្មោះឆាន សារី

កៈ
ចុះពូមានចងចាំថ្ងៃខែដែរពូបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទៅពូ?

ខៈ ខ្ញុំចាំតែឆ្នាំ1983នឹងលោកគ្រូ

កៈ នៅឆ្នាំ1983ហោសពូ ចុះពូមានចងចាំខែដែរទេពូ?

ខៈ ខែពូមិនចងចាំទេលោកគ្រូហើយ

កៈ ថ្ងៃក៏អត់ចាំដែរ?

ខៈ អត់ចាំទេ

កៈ ចឹងពូការអស់35ឆ្នាំពូ?

ខៈ នឹងហើយប៉ុណ្ណឹងឯង

កៈ ចុះនៅពេលដែរពូរៀបអាពាហ៍ពិពាហ៍នឹង
ដូចជាពូជាអ្នករៀបចំឡើងដោយខ្លួនឯងរឺឪពុកម្តាយពូ ជាអ្នករៀបអោយពូ?

ខៈ ឪពុកម្តាយជាអ្នករៀបអោយ

កៈ ចឹងឪពុកម្តាយពូជាអ្នករៀបចំអោយពូ?

ខ៖ បើគាត់ខាងនោះគាត់គ្មានឪពុកម្ដាយទេ អាពតបានសំលាប់អស់ហើយនឹង មានតែបងដែរនៅស្រែ នឹង

ក៖ ចឹងមានន័យថាខាងមីងបងប្អូនគាត់ជាអ្នករៀបអោយ?

ខ៖ បាទនឹងហើយ

ក៖ ចុះពូពេលដែរពូចូលស្ដីដណ្ដឹងមីងចឹងដូចជាមានជាថ្លៃទឹកដោះអត់ពូ?

ខ៖ កាលពីជំនាន់ណុងគ្មានថ្លៃទឹកដោះទេ

ក៖ ប៉ុន្តែយើងចេញរៀងខ្លួនមែនទេពូ?

ខ៖ បាទមិនមានថ្លៃទឹកដោះអីទេ គ្រាន់ថាយើងកូនប្រុសនឹង យើងទៅបំរើគេខាងស្រី នឹងដូចថាភ្ជួរស្រែ អីនឹងផ្ទះសំបែងនឹង

ក៖ និយាយរយមយើងធ្វើទាំងអស់តែម្ដងនឹង?

ខ៖ នឹងហើយផ្ទះសំបែងការងារខាងស្រីនឹងទៅ គេត្រូវការអីយើងត្រូវជួយគេ យើងបំរើគេចឹងទៅ

ក៖ ខ្ញុំលឺចាស់ដែរនៅស្រុកកំពង់រ៉ូលនឹងដែរចឹង មុននឹងយើងចូលស្ដីដណ្ដឹងនរណាគេម្នាក់នឹងគេអោយ យើងទៅបំរើគេមួយឆ្នាំសិនមែនទេពូ?

ខ៖ បាទៗនឹងហើយត្រូវ

ក៖ មុននឹងបានការចឹងទៅ?

ខ៖ នឹងហើយវាចឹង ប៉ុន្តែដល់សម័យរដ្ឋកម្ពុជារៀងធូរខ្លះដែរ

ក៖ ចឹងសម័យរដ្ឋកម្ពុជារៀងធូរហើយ?

ខ៖ ដល់ពេលមុនដែរសម័យរដ្ឋកម្ពុជានឹងគេអោយទៅ2-3ឆ្នាំហោសបានបាន មានតែអ្នកខ្លះផ្ដាប់ដល់ផ្ទះ ទៀតហោសបានគេអោយកូនស្រីនឹងវាចឹង

ក៖ ចឹងយ៉ាប់ហើយណពូ?

ខ៖ យ៉ាប់ដែរនឹងហាស មានស្រួលណា

ក៖ មិនដូចឥឡូវនឹងអោយតែត្រូវគ្នានឹងសឹងតែមិនចាំបាច់យកលុយទេនឹង?

ខ៖ បាទនឹងហើយមិនមែនស្រួលដូចឥឡូវនឹង

ក៖ អូ៎!យ៉ាប់ដែរចឹង ចុះពូអាចប្រាប់ខ្ញុំបានទេថាពូស្គាល់មីងប៉ុន្មានឆ្នាំដែរ ហើយហេតុអីបានជាពូ ស្រលាញ់មីងអីចឹង?

ខ៖ ស្រលាញ់អស់រយះពេលប្រហែលជា5-6ខែអីដែរនឹង

ក៖ អូ៎!អស់5-6ខែ ចុះស្គាល់គ្នាដោយរបៀបណាដែរពូ?

ខ៖ ខ្ញុំស្គាល់ដោយសារតែយើងធ្វើស្រែចឹងលោកគ្រូយើងទៅដក ស្ទូងអីចឹងទៅ ដល់ពេលហើយត្រូវគ្នា ពេលណុងទៅណា

ក៖ ហើយចឹងយើងក៏ទៅប្រាប់ឪពុកម្ដាយខាងយើងដើម្បីអោយចូលស្ដីដណ្ដឹងខាងគេទៅ?

ខ៖ ហើយក៏ចូលស្ដីដណ្ដឹងគេទៅណាស់

ក៖ ប៉ុន្តែពូធ្លាប់បានរៀនសូត្រពីមុនទេពូ?

ខ៖ ពូរៀនសូត្រកាលពីជំនាន់អាពតនឹង
កាលជំនាន់ណុងកំរិតវប្បធិមត្រឹមថ្នាក់ទី3ចុះមកក្រោមលោកគ្រូ
នរណាគេរៀនធ្លាក់ចាប់ពីថ្នាក់ទី1ទី2នឹងទី3ក៏ចុះមកក្រោមទៀតហើយនឹង

ក៖ អូ៎!ម៉េចចឹងពូ?

ខ៖ ពីព្រោះកំរិតវប្បធិមវាមកចឹងតែម្ដងនឹងនៅជំនាន់ពលពតនឹង
វាគិតថាមិនអោយវប្បធិមខាងក្រសួង អប់រំយើងអោយរីចំរើននោះទេនឹង

ក៖ អូ៎!គេធ្វើចឹងណាពូ?

ខ៖ នឹងហើយគេកំណត់ត្រឹមថ្នាក់ទី3តែម្ដងនឹង

ក៖ ចឹងត្រឹមថ្នាក់ទី3ចុះមកក្រោមវិញ?

ខ៖ បាទត្រឹមតែថ្នាក់ទី3ទេ នឹងគេប្រមូលជីអីមកដាក់ស្រែវិញនឹង
កាលពីជំនាន់អាពតនឹងគេកៀបហាសណាស់

ក៖ ចឹងពូរៀនបានថ្នាក់ទី3នឹង?

ខ៖ បាទរៀនបានថ្នាក់ទី3កាលពីជំនាន់អាពតនឹង

ក៖ ប៉ុន្តែកាលពីពូរៀននឹងតើពូរៀននៅណាដែរពូ?

ខ៖ ខ្ញុំរៀននៅស្រុកដែរនឹង

ក៖ ចុះពូមានចងចាំឈ្មោះសាលាដែរពូបានរៀនទេ?

ខ៖ ខ្ញុំចាំដែរតើ

ក៖ ឈ្មោះអីគេដែរពូ?

ខ៖ គេដាក់ឈ្មោះសាលារៀនស្អីទេនេះ វាដូចត្រងោលដូចជាគោកចឹងណាស់

ក៖ ប៉ុន្តែពូមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេពូ?

ខ៖ ពូមិនចេះអីទេក្មួយអើយ

ក៖ ចុះពូមានចេះភាសាវៀតណាមអីទេពូ ដោយសារតែពូនៅជិតនឹងវៀតណាមមែនទេពូ?

ខ៖ អត់មានចេះទេខ្ញុំខ្មែរសុទ្ធនឹង

ក៖ ពេលខ្លះវៀតណាមមកចឹងហើយវានិយាយចឹងទៅក្រែងវាចេះខ្លះដែរចឹងទៅ?

ខ៖ បាទអត់ចេះទេ

ក៖ ចឹងពូអត់ចេះទេណាពូ?

ខ៖ ប៉ុន្តែបើម្ដាយរបស់ខ្ញុំគាត់ចេះច្រើនតែម្ដងនឹង បើម្ដាយខ្ញុំគាត់ពូកែ
ប៉ុន្តែដល់ពេលដែរមកកូនៗអត់មាននរណាចេះទេ ទៅចឹងទៅ

ក៖ ចុះដូចជាពូធ្លាប់មានមិត្តភក្តិណាដែរធំធាត់មកជាមួយគ្នាទេ?

ខ៖ អត់មានទេគ្រូអើយ

កៈ លក្ខណៈមិត្តភក្តិស្និទ្ធិស្នាលហាសពូមានទេ?

ខៈ វាមានដែរប៉ុន្តែនៅស្រុកណោះ

កៈ អូ!មាននៅតែនៅស្រុកទេ ប៉ុន្តែមានច្រើនទេពូ?

ខៈ មានច្រើនដែរតើនឹង

កៈ ចុះពូអាចប្រាប់មួយចំនួនបានទេពូដែរពូគិតថាជាមិត្តភក្តិស្និទ្ធិណាពូ?

ខៈ ជិតស្និទ្ធិមានដូចជាក្មួយឃិតអីចឹងទៅ
អ៊ូ!ពិបាកចាំដែរនឹងដល់ពេលដែរចាស់ៗចឹងទៅនឹង

កៈ បាទអត់អីទេពូចឹងពូមានចងចាំថាកាលពីក្មេងដែរពូទៅរៀន នឹងពូទៅស្រែ
ដែរពូគិតថាមានអនុស្សាវរីយ៍អីជាមួយមិត្តភក្តិពូអីចឹងមានទេ?

ខៈ ចាំមានតើ ពេលណុងធ្វើជាស្រែចំការនឹង
ជួបគ្នាលេងសប្បាយដូចជាលេងសើចជាមួយគ្នាអីចឹងទៅ

កៈ ចុះសំរាប់ពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះណាពូ
គិតថាធ្លាប់ធ្វើការងារអីគេខ្លះដែរទៅពូ?

ខៈ កាលពីមុនអស់ពីធ្វើជាប្រធានមក គេអោយទៅធ្វើជាប្រធានក្រុម

កៈ ធ្វើជាប្រធានក្រុមហោសពូ?

ខៈ បន្ទាប់មកគេអោយពូធ្វើភូមិ
ដល់ពេលធ្វើជិតស្និទ្ធិចឹងទៅគេអោយយើងឡើងទៅជួរឃុំទៀតចឹងទៅ
វាចេះតែផ្ទុកៗចឹងទៅ

កៈ អ៊ូ!ល្អណាស់ពូ?

ខៈ ចុះយ៉ាងណាមួយយើងមិនចេះអក្សរចឹងចេះតែទៅៗនឹងណា នឹងរដ្ឋកម្ពុជានឹង

កៈ បាទរហូតដល់ពេលដែរពូមានគ្រួសារមកពូធ្វើអីគេដែរទៅ?

ខៈ ដល់ពេលដែរឥឡូវនឹងគ្មានធ្វើអីទេគ្រូ ទៅរត់តែម៉ូតូឌុបនឹង

ក៖  ចុះពូធ្លាប់ទៅធ្វើការងារនៅវាលស្រែចំការដែរណាពូ?

ខ៖  បាទធ្លាប់ដែរនឹង

ក៖  ប៉ុន្តែពេលណុងគេធ្វើអីគេខ្លះដែរទៅពូ?

ខ៖  ធ្វើស្រែចំការមានអីធ្វើមានតែដំណាំស្រូវនឹង

ក៖  ដូចជាដក ស្ទូងអីនឹងណាពូ?

ខ៖  នឹងហើយដក ស្ទូង ដាំបន្លែអីចឹងទៅ

ក៖  ប៉ុន្តែពូមានធ្លាប់បើអាជីវកម្មលក់ដូរអីទេពូ?

ខ៖  កាលពីមុនមានលក់ដែរនឹង

ក៖  ពូលក់អីគេខ្លះដែរពូ?

ខ៖  កាលពីមុននឹងមានលក់ផ្លែឈើអីដែរ
តែដល់ពេលឥឡូវនឹងលក់វាមិនបានដូចជាបំណងហាស
ណាស់លោកគ្រូយ៉ាងណាមួយចេះតែដកដើម

ក៖  លក្ខណះចេះតែខាតហោសពូ?

ខ៖  នឹងហើយមិនបានរីកចំរៀនទេដល់ពេលចឹងទៅ

ក៖  ចុះពូមានធ្លាប់ចិញ្ចឹមសត្វទេពូ កាលពីពូនៅក្មេងចឹងហាស ដូចជាចិញ្ចឹមគោ ចិញ្ចឹមមាន់ ចិញ្ចឹមទា ជ្រូកអីចឹងទៅមានទេពូ?

ខ៖  អូ៎!អានឹងខ្ញុំចិញ្ចឹមច្រើនណាស់លោកគ្រូអើយ

ក៖  លក្ខណះចិញ្ចឹមជាកសិដ្ឋាន រឺមួយក៏ចិញ្ចឹមជាគ្រួសារដែរពូ?

ខ៖  ទេយើងចិញ្ចឹមជាគ្រួសារដែរនឹង

ក៖  នឹងគ្រាន់តែពូចិញ្ចឹមច្រើនដែរណាពូ?

ខ៖  តែបើចិញ្ចឹមមាន់ទាអីនឹង ចិញ្ចឹមលក្ខណះជា50-
60ក្បាលអីចឹងទៅពេលខ្លះ100ក្បាលក៏មានដែរ

កៈ អូ!ចិញ្ចឹមច្រើនណាស់ណចង់ចូលជាលក្ខណៈកសិដ្ឋានហើយនឹង?

ខៈ បាទនឹងហើយប៉ុន្តែវាមានទ្រុងរបស់វាទៅណាស់
ដូចថាមានទ្រុងនៅក្រោយផ្ទះពីរទៅបីអីចឹងទៅណាស់

កៈ ចុះពូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស
តើជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរទៅពូ?

ខៈ ដូចជាគ្មានអីត្រូវផ្លាស់ប្តូរទេគ្រូ

កៈ និយាយការផ្លាស់ប្តូរទាំងអស់ហាសពូ?

ខៈ ដូចជាផ្លាស់ប្តូរកិច្ចការរកស៊ីអីនឹង

កៈ ដូចថាពេលដែរពូនៅកំលោះ រឺមួយក៏ពូនៅក្មេងមានរឿងអីកើតឡើងចឹងទៅ
ហើយពេលដែរពូមាន ក្រុមគ្រួសារ
នឹងពេលដែរពូមានកូនពូមានបញ្ហាអីកើតឡើងចឹងទៅណាស់ពូ?

ខៈ អត់មានទេក្មួយអើយ

កៈ អត់មានទេណាពូ ចុះពូគិតថាពូចូលចិត្តពិសារម្ហូបអីគេខ្លះដែរទៅពូ?

ខៈ ពូចូលចិត្តពិសារម្ហូបម្ជូរ ដូចថាម្ជូរបន្លែ
នឹងម្ជូរព្រលិតចឹងទៅដែរមើលទៅសមរម្យចឹងទៅ

កៈ ចុះគេហៅម្ជូរអីគេ ម្ជូរស្រែមែនទេពូ?

ខៈ បាទម្ជូរស្រែ

កៈ ដែរគេហៅម្ជូរត្រកួននឹងហោសពូ?

ខៈ បាទនឹងហើយម្ជូរត្រកួននឹង

កៈ វាឆ្ងាញ់ណាពូ ចុះពូតាំងពីក្មេងពូចូលចិត្តលេងល្បែងប្រជាប្រិយ៍ទេដែរពូធ្លាប់លេងពូ
ដូចជាចោលឈូង ទាញព្រាត លាក់កន្សែង

ខៈ អូ!ល្បែងមួយនឹងចូលចិត្តលេងណាស់

កៈ មួយនឹងពូចូលចិត្តលេង?

ខៈ វាសប្បាយណាស់

កៈ ប៉ុន្តែភាគច្រើនពូទៅលេងនៅណាដែរពូ?

ខៈ លេងនៅវាលស្រែនឹង

កៈ ចុះលក្ខណៈថាលេងតាមវត្ត រឺមួយក៏លេងតាមភូមិ ដែរពូ?

ខៈ នឹងហើយលេងតាមភូមិ តាមវត្ត តាមសាលាអីចឹងដែរទៅ

កៈ ភាគច្រើនពូលេងពេលណា?

ខៈ ដល់ណាក៏ដោយ ហើយយើងលេងចឹងយើងណាត់គ្នាលេងទាំងស្រី
ទាំងប្រុសអីចឹងទៅ

កៈ ប៉ុន្តែភាគច្រើនពូលេងនៅពេលណាដែរពូ លេងនៅពេលដែរកៀកចូលឆ្នាំមែនពូ?

ខៈ លេងពេលចូលឆ្នាំ និយាយអោយចំទៅលេងពេលដែរចូលឆ្នាំនឹងឯង
នឹងហើយលេងទាញព្រាតចឹង លេងតាមវត្តតាមអារាមចឹងទៅណាស់

កៈ ប៉ុន្តែពូមានចេះច្រៀងដែរទេពូ?

ខៈ ពូចេះច្រៀងតិចៗដែរនឹងប៉ុន្តែឥឡូវនឹងភ្លេចអស់ហើយលោកគ្រូអើយ

កៈ ប៉ុន្តែពូចូលចិត្តស្តាប់បទចំរៀងណាស់ពូ?

ខៈ បាទចូលចិត្តស្តាប់ដែរតើ

កៈ ប៉ុន្តែលក្ខណៈជាបទសម័យរឺមួយក៏បទពីដើមដែរពូ?

ខៈ ចូលចិត្តស្តាប់បទពីដើមនឹង ប៉ុន្តែបើបទសម័យមិនសូវចូលចិត្តស្តាប់ទេ

កៈ ពីព្រោះវាពិបាកស្តាប់ដែរពូ?

ខៈ នឹងហើយពិបាកស្តាប់ដែរនឹង

កៈ ចុះពូមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់ពូចេះលេងឧបករណ៍ភ្លេងដែរទេពូ?

ខ៖ អូ៎!អត់មានទេគ្រូអើយ

ក៖ លក្ខណៈថាភ្លេងខ្មែរ នឹងភ្លេងពិពាតអីចឹងពូ?

ខ៖ បើសិនជាឪពុករបស់ខ្ញុំគាត់ស្លាប់ទៅនឹងគាត់ជាអ្នកភ្លេងដែរនឹង

ក៖ លក្ខណៈភ្លេងអីគេដែរពូ?

ខ៖ លក្ខណៈការ

ក៖ អូ៎!ភ្លេងការហោសពូ?

ខ៖ នឹងហើយភ្លេងប្រពៃណីនឹង

ក៖ អូ៎!ល្អដែរនឹងពូ
ចុះពូគិតថាផ្ទះរបស់ពូមានលក្ខណៈបែបណាដែរពូតាំងពីក្មេងរហូតមកដល់ពេលនេះហោសពូ?

ខ៖ និយាយរួមទៅធ្វើដូចតែគេដូចតែឯងនឹងលោកគ្រូ

ក៖ ប៉ុន្តែលក្ខណៈថាកាលពីនៅក្មេងផ្ទះធំរឺក៏តូច ហើយឥឡូវនឹងផ្ទះស្អាតចឹងទៅ?

ខ៖ នឹងលោកគ្រូអើយ នឹងបានតែនៅស្រុកស្រែនឹងលោកគ្រូ
គ្រាន់តែខ្ញុំដឹងថាឪពុករបស់ខ្ញុំធ្វើដូចគេនឹង ដូចតែឯងនឹង មានផ្ទះអីចឹងទៅណាស់

ក៖ ដល់ពេលឥឡូវនឹងផ្ទះរបស់ពូស្អាត?

ខ៖ បាទមានតែប៉ុណ្ណឹង

ក៖ ចុះពូគិតថាសាងសងផ្ទះពូនឹងគិតថាឧបករណ៍អីគេខ្លះដែរសំរាប់សាងសងដែរពូ?

ខ៖ សាងសងណា ដូចជាជាលក្ខណៈដូចផ្ទះដែរចឹងទៅ
ហើយយើងមិនប្រើប្រកូលបុកគ្រឹស្វទេណាស់

ក៖ អូ៎!ពូធ្វើចឹងណាពូ?

ខ៖ យើងបុកប្រកូលតិចៗចឹងណាស់ មានបុកចាក់ក្រវ៉ាត់អីចឹងទៅ
ហើយចាក់សសរផ្ទះចឹងទៅ

កៈ ចុះប៉ុន្តែផ្ទះរបស់ពូនឹងនរណាគេជាអ្នកសាងសង់ រឺក៏ពូជួលគេដែរពូ?

ខៈ ខ្ញុំជាអ្នកធ្វើដោយខ្លួនឯងដែរ

កៈ អូ៎!ពូចេះធ្វើផ្ទះហោសពូ?

ខៈ ធ្វើតែខ្លួនឯងប៉ុន្តែយើងត្រូវរកកំលាំងគេអោយជួយណា
អោយជួយលើកនេះលើកនោះអីចឹងទៅ

កៈ ចុះនរណាគេជាអ្នកបង្រៀនអោយពូចុះធ្វើផ្ទះដែរពូ?

ខៈ ទេនេះចិត្តដុះរបស់យើងនឹង

កៈ អូ៎!យើងទៅមើលគេហោសពូ?

ខៈ បាទយើងទៅមើលគេធ្វើដែរនឹង លួចមើលគេទៅធ្វើតាមគេចឹងទៅ

កៈ ចឹងមានន័យថាជំនាញរបស់ពូគឺធ្វើផ្ទះនឹង?

ខៈ ធ្វើផ្ទះនឹងហើយ

កៈ ចុះពូមានចេះធ្វើអីផ្សេងពីនឹងទៀតទេពូ?

ខៈ រឿងស្អីផ្សេងនឹងគ្រាន់តែថាពូចាស់ហើយពូធ្វើវាមិនកើត
ប៉ុន្តែផ្ទះថ្មអីពូចេះធ្វើដែរនឹងគ្រាន់តែថាលក្ខណះតូចតាចហាស
បើធំដូចជាសណ្ឋាគារអីយើងធ្វើមិនកើតទេនឹង

កៈ ចុះឪពុកម្តាយរបស់ពូគាត់មានធ្លាប់បង្រៀនអីទៅពូដែរទេដូចជាបង្រៀនធ្វើផ្តៅ កូរស្ក
ធ្វើកន្ទេល ធ្វើជាអញ្ចូតពូចេះទេ?

ខៈ និយាយពីកន្ទេលហោស?

កៈ កន្ទេលអញ្ចូតអីចឹងហោសពូចេះទេ?

ខៈ ខ្ញុំចេះធ្វើដែរនឹងធ្វើកន្ទេលអញ្ចូតនឹង

កៈ អូ៎!ពូចេះដែរហោសពូ
ដោយសារតែអ្នកនៅខាងស្វាយរៀងភាគច្រើនគេធ្វើកន្ទេលអញ្ចូតណាពូ?

ខ៖  បាទថ្ងើកន្ទេលអញ្ចូតនឹង

ក៖
ចុះពូអាចប្រាប់ថាពេលណាដែរពូគិតថាជាពេលដែរពិបាកជាងគេនៅក្នុងឆាកជីវិតរបស់ពូបានទេ តាំងពីក្មេងរហូតមកដល់ពេលនេះពូ?

ខ៖  តាំងពីក្មេងនឹង

ក៖  តាំងពីក្មេងពូមានការលំបាកអីគេចឹងពូ?

ខ៖  បើនិយាយពីក្នុងសង្គ្រាមបានទេគ្រូ?

ក៖  បាទៗពូអាចនិយាយកន្លែងណាដែរពូចងចាំណាពូ?

ខ៖  ពីជំនាន់ដូចខ្ញុំនិយាយចឹងដល់ឆ្នាំទសវត្ស1970ណាគ្រូ

ក៖  បាទពូបាទនឹង?

ខ៖  កាលនៅជំនាន់ណុងគេថាទាហ៊ាន លុនណុល
នឹងទាហ៊ានគេហៅខ្មែរក្រហមយាកកុងអីនឹងណា នឹងហើលាយឡុំគ្នាចឹងទៅ

ក៖  មានការលាយឡុំគ្នាទៅ?

ខ៖  នឹងហើយដោយសង្គ្រាមដែរគេចដោយគ្រាប់ទេនឹង ទៅនេះវៃគ្នាទៅ
នោះវៃគ្នាចឹងទៅណាស់ឡើង ផ្អើលចឹងទៅគ្មានអោយស្ងប់ទេក្មួយអើយ
គេវៃគ្នារាល់តែថ្ងៃនឹង ហើយយើងរត់គេចតែគ្រាប់នឹង បានការលំបាកវេទនាណាស់នឹង

ក៖  ពូខ្ញុំសុំសួរបន្តិចពូ?

ខ៖  សួរអីគេដែរគ្រូ

ក៖  ដូចជាគេហៅជំនាន់យាកកុង យាកកុងនឹងអីគេដែរពូ?

ខ៖  យាកកុងនឹងគេហៅវៀតណាមនឹងណា

ក៖  អ្ហូ!វៀតណាមហោសពូ ចឹងគេហៅកងទ័ពយាកកុងចឹងទៅ?

ខ៖  នឹងហើយកាលពីជំនាន់ណុងគេហៅទ័ពយាកកុងនឹង នឹងជាភាសាវៀតណាមណា

កៈ មកពីខ្ញុំវាមិនដឹងនឹង?

ខៈ ខ្មែរយើងនឹងគេហៅតែទាហ៊ានយួននឹង

កៈ ចុះរហូតមកដល់ជំនាន់ពលពតគេអោយពូធ្វើអីគេដែរទៅ?

ខៈ ជំនាន់ពលពតគ្មានធ្វើអីទេគ្រូ ជំនាន់ពលពតឃ្វាលគោ

កៈ អូ៎!ពូជាអ្នកឃ្វាលគោណពូ?

ខៈ ឃ្វាលគោអោយទៅសហករគេណាស់

កៈ ប៉ុន្តែពេលណុងពូនៅណាដែរពូ?

ខៈ កាលណុងពូនៅស្វាយរៀងដែរនឹង

កៈ ប៉ុន្តែគេមានជំលាសពូទៅណាផ្សេងទៀតអត់ពូ?

ខៈ មានតើ

កៈ ពូទៅកន្លែងណាដែរពូ អាចរៀបរាប់ខ្លះៗបានទេពូ?

ខៈ បានតើ បើនិយាយទៅវាវែងណាស់គ្រូអើយ

កៈ ពូអាចរៀបរាប់អ្វីដែរពូបានចងចាំណាស់ពូ?

ខៈ
ដល់ពេលដែរសង្គ្រាមទៅជំនាន់ណុងលោកគ្រូអើយមានការចាប់មនុស្សដូចថាជាជំនាន់ខ្មែរក្រហម លក្ខណៈថាផ្តាច់ការចឹងទៅណាស់
ប៉ុន្តែខ្ញុំនិយាយនេះមិនអោយប៉ះពាល់ដល់រដ្ឋាភិបាលយើងទេនឹង

កៈ បាទត្រូវហើយពូ?

ខៈ ដល់ពេលចឹងទៅអាពតដូចថាក្រុមគ្រួសារណាដែរមានអាពតច្រើននឹងមួយភូមិរឺមួយឃុំសង្កាត់ឈើ ទាលហាស នៅខេត្តស្វាយរៀង
នៅខាងឈើទាលខាងក្រោលគោហាសគ្រូ

កៈ យ៉ាងម៉េចទៅពូ?

ខ៖ កាលពីជំនាន់ណុងខ្ញុំអាយុ13ឆ្នាំណាស់ដល់ពេលណុងខ្ញុំទៅឃ្វាលគោ ដល់ពេលហើយបានឃើញ ពួកខ្មែរក្រហមនឹងឃើញវាបណ្តើរប្រជាជនណាស់ វាបណ្តើរទាំងខ្សែៗនឹង

ក៖ គេបណ្តើរយកទៅណាដែរពូ?

ខ៖ បណ្តើរមួយខ្សែៗនឹងស្មើរដើមបំពង់យើងណាស់មួយដើមវែងៗនឹងមាន6-7ម៉ែត្រចឹងណាស់ វាបានចងគ្រាកប្រជាជនចឹងណាស់ ចងស្លាបគ្រាកទៅក្រោយចឹងណាស់

ក៖ ចងទាំងស្រីទាំងប្រុសចឹងទៅ?

ខ៖ ចងតែប្រុសៗទេ

ក៖ ចឹងចងតែប្រុសៗទេនឹងពូ?

ខ៖ បាទសុទ្ធតែប្រុសនឹង ចងគ្រាកៗហើយស្វកបំពង់ឬស្សី មួយដើមបំពង់មានគ្នាជិត20នាក់នោះ ហើយខ្ញុំឃើញគេខ្ញុំក៏ភ័យដែរនឹង មកពីខ្ញុំភ័យដោយសារតែខ្ញុំមកឃ្វាលគោនៅកន្លែងនឹងដែរនឹង

ក៖ ចុះគេមានធ្វើអីដាក់ពូដែរទេ?

ខ៖ អត់មានធ្វើអីទេប៉ុន្តែអាពតវាមកផ្ទុងកាំភ្លើង ហើយវាចងបិទមុខ

ក៖ នឹងគេយកទៅវៃចោលមែនពូ?

ខ៖ នឹងគេយកទៅវៃចោលនឹងហើយ ដល់ពេលដែរគេចងបិទមុខហើយមានម្នាក់អ្នកបញ្ជា ម្នាក់អ្នកដឹក ពីមុខហើយគេអ្នកខាងក្រោយមកផ្ទុងកាំភ្លើងតាម

ក៖ អូ៎!ចឹងពូម៉េចទៅ?

ខ៖ ភ័យដែរនឹង ហើយមានពីរនាក់ទៀតនឹងចាំរុញអាដងបំពង់នឹង រុញអោយលឿនៗទៅៗ វានិយាយទៅ ថាអោយលឿនៗៗហើយវាទាញហើយពួកគេនឹងចេះតែរត់តាមទៅអ្នកដែរត្រូវគេចងទៅណាស់

ក៖ អូ៎!ពេលពូឃើញចឹងពូធ្វើយ៉ាងម៉េចទៅ?

ខ៖ ដល់ពេលចឹងទៅខ្ញុំឃើញខ្ញុំក៏ទៅពួននៅវាលស្រែចឹងទៅ
ខ្ញុំខ្លាចគេឃើញដែរនឹងតែគេឃើញនឹង ខ្លាចគេចាប់យើងទៅដោយដែរនឹង

ក៖ អ្ហ៎!បាទត្រូវហើយពូ?

ខ៖ ហើយដល់ខ្ញុំចាំមើលគេទៅទាល់តែផុតបានខ្ញុំដេញគោទៅតាមក្រោយ
ដេញគោទៅសហាករវិញទៅ

ក៖ ប៉ុន្តែគេធ្វើខុសអីមែនពូ?

ខ៖
គេគ្មានធ្វើខុសអីទេលោកគ្រូប៉ុន្តែដូចថាជំនាន់ណុងជានយោបាយរបស់គេចឹងណាស់ពេល
បែកពី លុនណុលនឹងដូចថាគេយកប្រជាជនចាស់នឹងប្រជាជនថ្មីទាំងអស់នឹង
ប្រុសៗនឹងនរណាដែរមានអាយុ ចាប់ពី20ឆ្នាំឡើងទៅនឹងគេចោទថាជាCEAនឹង

ក៖ CEAនឹងជាអ្វីទៅពូ?

ខ៖ លក្ខណៈថាជាពួកទ័ពរបស់អាមេរិច
នឹងចឹងពួកអាមេរិចនឹងមួយទៀតគេចោទយើងថាពួកអាក្បាលស

ក៖ អ្ហ៎!ចឹងហោសពូ?

ខ៖ ហើយពួកគេចាប់ប្រុសៗទាំងអស់ពេញមួយភូមិនឹងចាប់យកទៅទាំងអស់នឹង

ក៖ ប៉ុន្តែចាប់ពីអាយុ20ឆ្នាំឡើងទៅមែនទេពូ?

ខ៖ នឹងហើយចាប់ពីអាយុ20ឆ្នាំឡើងនឹង

ក៖ ប៉ុន្តែពេលនឹងពូនៅអាយុ13ឆ្នាំទេ?

ខ៖ នឹងហើយខ្ញុំអាយុ13ឆ្នាំនឹង

ក៖ ប៉ុន្តែម៉េចចាប់ពូទៅទៅ?

ខ៖ គេមិនចាប់ខ្ញុំទេនឹង

ក៖ ប៉ុន្តែពូខ្លាចដែរហោសពូ?

ខ៖ នឹងហើយខ្ញុំខ្លាចដល់ពេលដែរស្អែកព្រឹកឡើងនឹងខ្ញុំមកឃ្វាលគោនៅម្ដុំនឹងទៀតនឹង

ក៖ ចុះពេលណុងមានរឿងអីទៀតទេ?

ខ៖ លោកគ្រូអើយគេវៃចោលសុទ្ធតែដងចបហោសគ្រូ
អាដងចបប៉ុនៗកដៃនឹងវៃបោះចូលអន្លង់រណ្ដៅ នឹងគេគ្មានបានយកទៅកប់ចោលទេ

ក៖ ប៉ុន្តែពេលដែរគេវៃចឹងអ្នកស្លាប់ៗទៅអ្នកដែរនៅរស់ក៏នៅរស់ចឹងទៅហោសពូ?

ខ៖ ទេគ្មាននរណាគេនៅរស់ទេនឹង
គេវៃអ្នកនៅណុងតែវៃហើយគ្មានអ្នកនៅរស់ទេស្លាប់ទាំងអស់នឹង

ក៖ ធម្មតាគេវៃមួយដងចបមែនទេពូចឹងមួយដងចបមិនទាន់ស្លាប់ទេណាពូ?

ខ៖ ទេមួយដំបងចបណាស់

ក៖ អូ៎!មួយដំបងចបហោសពូ?

ខ៖ នឹងហើយមួយដំបងចបហាសគ្រូ
ដំបងចបនឹងសុទ្ធឈើនាងនួននឹងមិនមែនឈើធម្មតាណា

ក៖ គេមិនប្រើឈើធម្មតាទេណាពូ?

ខ៖ មិនមែនទេហើយដងចបនឹងសុទ្ធប៉ុនកំភួនដៃណោះ

ក៖ មិនមែនគេបាញ់ទេណាពូ?

ខ៖ គេមិនបាញ់ទេគេវៃតែម្ដងនឹង
គេវៃចំកញ្ចឹងកតែម្ដងនឹងតែវៃធ្លាក់ទៅក្នុងអន្លង់ហើយរើម៉េចរួចគ្រូ

ក៖ បាទពូដោយសារតែគេកប់លើគ្នាណាពូ?

ខ៖ នឹងហើយតែត្រូវនឹងទៅហើយនឹង

ក៖ ពូទៅមើលគេហោសពូ?

ខ៖ ពេលដែរខ្ញុំទៅមិនគេមិនទាន់បានកបទេ
គេបំរុងយកមនុស្សមកវៃដាក់បន្ថែមទៀតណាស់មួយអន្លូង
នឹងមាន5ម៉ែត្របួនជ្រុងនឹងហើយ

ក៖ អូ៎!ធំៗដែរនឹងពូ?

ខ៖ ធំៗរួចដូចថាគេយកចំនួនមនុស្សប៉ុន្មានហើយគេមកជីករណ្ដៅនឹងប៉ុន្មានហើយ

ក៖ គេសុទ្ធត្រៀមហើយហើយ?

ខ៖
នឹងគេយកមកប៉ុន្មានដូចថាប្រហែលជា50នាក់ចឹងគេជីករណ្ដៅធំចឹងទៅដូចថាមាន10ម៉ែត្រអីចឹង

ក៖
ចឹងពូមានដឹងថាកាលពីជំនាន់ពលពតគេវៃអស់ប៉ុន្មានលានអ្នកអីទេដែរគេវៃខ្មែរហាសពូ?

ខ៖ គេវៃអស់ច្រើនណាស់លោកគ្រូ

ក៖ ប៉ុន្តែគ្រាន់តែអត្រាភាគរយច្រើនណាពូ?

ខ៖
ដូចថាកាលពីមុនគេនិយាយពីឆ្នាំ1979នឹងកាលណុងខ្ញុំក៏ធ្វើទ័ពដែរគេថាអស់3លានអ្នក

ក៖ អូ៎!អស់3លានអ្នកច្រើនដែរនឹង?

ខ៖ បាទបើតាមខ្ញុំគិតទៅដូចជាអស់ជាង6លានអ្នក

ក៖ ជាង6លានអ្នកហោសពូច្រើនណាស់ពុ?

ខ៖ អូ៎!ច្រើនលែងនិយាយហើយ

ក៖ ប៉ុន្តែកាលពីជំនាន់ណុងមានមនុស្សចំនួនប៉ុន្មានលានអ្នកសំរាប់ប្រជាជនខ្មែរយើង?

ខ៖ ខ្ញុំចាំបានចេះកាលណុងជំនាន់សម្ដេចតាខ្ញុំកើតទាន់បាន8ទៅ9ឆ្នាំដែរនឹង

ក៖ ពូនៅអាយុ8-9ឆ្នាំដែរ?

ខ៖ កាលណុងខ្ញុំទាន់សម្តេចតាយើងនឹង គេនិយាយថាជំនាន់សម្តេចតានឹងមានទាំងក្មេង ទាំងចាស់ ទាំងស្រីនឹងទាំងប្រុស ទាំងអស់នឹងមាន15លានអ្នក

ក៖ អូ៎!មាន15លានអ្នកណាពូ?

ខ៖ នឹងហើយមាន15លានអ្នក ហើយអ្នកដែរបំពេញអាយុចាប់ពីអាយុ18ឆ្នាំឡើងទៅនឹងវាមានជាង 7លានអ្នកណាស់លោកគ្រូ ហើយធនធាននឹងវាបាត់អស់រលីងចឹងទៅ

ក៖ បាទវាមានច្រើនណាស់ពូ?

ខ៖ វាទៅបាត់សឹងអស់ហើយនឹង

ក៖ ចឹងមានន័យថាគ្រាន់តែពលពតវៃនឹងវាសឹងតែពាក់កណ្តាលបាត់ទៅហើយនឹងពូ?

ខ៖ វាពាក់កណ្តាលហើយនឹងណាវាជាង6លានអ្នកហើយនឹង

ក៖ អូ៎!ចឹងបានជាខ្មែរយើងវាបាត់អស់មនុស្សច្រើននឹងពូ?

ខ៖ អូ៎!អស់អីនិយាយហើយគ្រូវាមានច្រើនពេកទៅ

ក៖ ចុះដល់ពេលណុងពូមានធ្វើអីផ្សេងទៀតទៅពូបន្ទាប់ពីពូទៅឃ្វាលគោហើយចឹងទៅ?

ខ៖ ហើយបន្ទាប់ពីឃ្វាលគោហើយនឹង ហើយក៏ចូលប្រហែលរយះពេលមួយខែនៅឆ្នាំ1977នឹង

ក៖ នៅឆ្នាំ1977ពូធ្វើអីទៅ?

ខ៖ ពេលដែរឆ្នាំ1977នឹងគេជំលាសខ្ញុំមកខេត្តបាត់ដំបងនឹងវិញ កាលពីជំនាន់អាពតនឹងគេថាអោយក្រុម គ្រួសារខ្ញុំទៅធ្វើនយោបាយទៅ

ក៖ ប៉ុន្តែពូគិតយ៉ាងម៉េចដែរ?

ខ៖ គេថាអោយបាយមួយថ្ងៃ3ពេល ចំណែកផ្លែឈើមិនខ្វះស្អីៗហូបទេពីព្រោះនៅបាត់ដំបងនឹងមានអីៗ ច្រើនដែរ

ក៖ នឹងជានយោបាយគេមែនពូ?

ខ៖
នឹងហើយជានយោបាយគេដល់ហើយគេដាក់បញ្ជូននៅលើនេះគេដេញយើងមកទាំងយប់
នឹងឡាន នឹង

ក៖ គេអោយទៅទាំងយប់ណាពូ?

ខ៖ បាទហើយគេអោយឡើងកប៉ាល់នឹងក៏ទាំងយប់ទៀតដែរ
ហើយឡើងមកដេកនៅផ្សារច្បារអំពៅយើងនឹងណា ហើយទីក្រុងភ្នំពេញនឹងវាស្ងាត់

ក៖ នៅភ្នំពេញនឹងវាស្ងាត់ដោយសារតែគ្មានមនុស្សនៅណាពូ?

ខ៖ នឹងហើយស្ងាត់ឈឹងតែម្ដងនឹង គេបានដឹកពីច្បារអំពៅមកទៅឡើងនៅរ៉ារទេះភ្លើង

ក៖ ប៉ុន្តែគេមានឡានដឹកតៗៗរហូតដែរតើហីពូ?

ខ៖ ដល់ពេលនេះគេគ្មានឡានទេគេប្រើរទេះភ្លើងម្ដងនឹង

ក៖ អូ!គេប្រើរទេះភ្លើងណាពូ?

ខ៖ គេប្រើអាអូតូរ៉ៃនឹង

ក៖ នឹងកាលពីជំនាន់មុនណាពូ?

ខ៖ បាទប៉ុន្តែឥឡូវនឹងគេបានបាត់អូតូរ៉ៃហើយនឹង គេនៅតែរទេះភ្លើងនឹងណា

ក៖ ប៉ុន្តែពេលដែរពូទៅបាត់ដំបងពូបានធ្វើអីគេដែរទៅពូ?

ខ៖ ដល់ពេលដែរបានទៅដល់បាត់ដំបងទៅ
នៅកន្លែងគេនឹងបានបំបែកគ្នាអស់រលីងនឹងលោកគ្រូអើយ នឹងហើយនារីទៅដោយនារី
ឯបុរស់ទៅដោយបុរស់ ឯកុមារទៅដោយកុមារ

ក៖ អូ!គេបែងចែកគ្នាណាពូ?

ខ៖ នឹងហើយគេអោយណុងគេហៅយាកវ៉ាងហាស

ក៖ គេហៅកងទ័ពយាក់វ៉ាង?

ខ៖ នឹងហើយយាក់វ៉ាងនារីទៅដោយនារី
យាក់វ៉ាងកុមារទៅដោយកុមារគេបានបំបែកពីម៉ែឪអស់ហើយ នឹងគេមិនអោយនៅជុំគ្នាទេ

ក៖ អូ៎!នៅផ្សេងៗៗពីគ្នាទាំងអស់ចឹងពូ?

ខ៖ បាទចាស់ៗនៅវ៉ៃយកណ្ដាលអ្នកខ្លះមើលកូនទៅ អ្នកខ្លះមើលចៅទៅ
ហើយបើយាយអីនឹងមើលកូន នឹងមើចៅៗអីចឹងទៅណាស់

ក៖ គាត់មើលកូនគេ កូនឯងចឹងទៅ?

ខ៖ នឹងហើយមើលកូនគេ កូនឯងចឹងទៅណាស់កាលពីជំនាន់ពលពតនឹង
ហើយកូនចៅចេះតែស្រែ ឡើងរញ៉េរញ៉ៃចឹងទៅដូចរូបខ្ញុំនៅអង្គភាពកុមារដែរនឹង

ក៖ ប៉ុន្តែពូពេលណុងជាអង្គភាពកុមារប៉ុន្តែនៅណាដែរពូ?

ខ៖ អង្គភាពកុមារនឹងទៅនៅកណ្ដាលព្រៃតែម្ដងនឹង

ក៖ អោយយើងទៅនៅកណ្ដាលព្រៃទៅ?

ខ៖ នឹងហើយគេមានមេកងធំគេអោយរៀបចំមើល
មានកន្លែងដេកអីចឹងដែរគេអោយដេកមួយជួរចឹងទៅ សំរាប់កូនក្មេងនឹង
និយាយទៅវេទនាណាស់លោកគ្រូ

ក៖ អូ៎!បាទពិតជាវេទនាណាស់ពូ?

ខ៖ អាខ្លះក៏យំទៅ

ក៖ ប៉ុន្តែពេលណុងគេលែងអោយពូនៅជាមួយគ្រួសារហើយមែនទេពូ?

ខ៖ គេលែងអោយនៅជាមួយគ្រួសារទៀតហើយនឹង នៅដោយអង្គភាពកុមារតែម្ដងនឹង

ក៖ ប៉ុន្តែគ្រួសាររបស់ពូគេអោយទៅណាដែរទៅនឹងពូ គេជំលាសទៅណាដែរពូ?

ខ៖ គេជំលាសទៅបាត់ដំបងនឹងលោកគ្រូ

ក៖ អូ៎!និយាយរួមទៅគេជំលាសទាំងគ្រួសារទៅ
ប៉ុន្តែគ្រាន់តែពូគេអោយទៅដេកជាមួយនឹងកុមារ?

ខ៖ នឹងហើយវាចឹងខ្ញុំទៅតែខាងអង្គភាពកុមារហើយ យើងទៅនៅណុងដូចថាម៉ែឪគ្រួសារដូចថាមិននៅ ជិតគ្នាទេគឺនៅបែកគ្នាទៅប្រហែលជា3-4គីឡូដីណោះ

ក៖ អ៊ូ!ឆ្ងាយដែរពូ?

ខ៖ នឹងហើយនៅបែកគ្នានឹង

ក៖ ប៉ុន្តែបងរបស់ពូក៏នៅបែកគ្នាដែរហោសពូ?

ខ៖ ពួកគាត់ក៏នៅបែកគ្នាដែរទាំងអស់នឹង

ក៖ ប៉ុន្តែដូចជាបងៗរបស់ពូដូចជាស្លាប់នៅជំនាន់ពលពតរឺយ៉ាងណាដែរពូ?

ខ៖ អត់ទេគាត់ស្លាប់នៅសម័យរដ្ឋកម្ពុជា

ក៖ ចឹងមានន័យថាជំនាន់ពលពតវាចប់ហើយណាពូ?

ខ៖ បាទវាចប់ហើយនឹង ហើយដល់ពេលទៅដល់ណុងគ្មានអីទេគ្រូកុមារនឹងគេអោយទៅច្រូតតែស្រូវនឹង

ក៖ កុមារគេអោយធ្វើចឹងហោសពូ?

ខ៖ នឹងគេអោយច្រូតហើយនឹងរែកកណ្តាប់អីចឹងទៅណាស់លោកគ្រូ មិនថាយ៉ាងម៉េចទេនៅដេកយាម កណ្តាប់នឹងទៀតបានកើត

ក៖ ចឹងយើងត្រូវយាមទៀតណាពូ?

ខ៖ មិនត្រឹមតែយាមទេ យើងត្រូវទៅបើកកណ្តាប់នឹងទៀត ប៉ុន្តេធ្វើការនៅសម័យអាពតនឹងមិនមែនធ្វើ ដូចយើងណា

ក៖ គេធ្វើយ៉ាងម៉េចទៅពូ?

ខ៖ កាលពីជំនាន់អាពតគេចាប់ធ្វើការគ្មានអោយដេកទេ ទាល់តែដល់ម៉ោង10យប់បានគេអោយលែង បានគេលែងអោយយើងធ្វើការងារនឹង

ក៖ គេមានម៉ោងគេដែរហោសពូ?

ខ៖  គេកំណត់ពេលដែរនឹងហើយដល់ពេលដែរបានដល់ម៉ោង10យប់យើងមិនដេក ដល់ពេលដេកបាន តែប៉ុន្មានម៉ោងភ្លឺវិញនឹង គេអោយយើងទៅច្រុតទៀតហើយនឹង នឹងវាចឹងគេប្រដៅយើងណាស់គ្រូ

ក៖  ចឹងយើងធ្វើវាចឹងរហូតទៅ?

ខ៖  នឹងហើយដល់ពេលដែរទៅច្រូតទៀតទៅនិយាយរួមវាវែងឆ្ងាយណាស់លោកគ្រូអើយ

ក៖  ចុះពេលដែរពូចប់ពីបាត់ដំបងវាដាច់តែម្តងរឺមួយយ៉ាងណាដែរពូ?

ខ៖  អត់ទេវាបានប្រហែលជា5-6ខែ
បានមានទាហ៊ានវៀតណាមគេមករំដោះណាស់លោកគ្រូ

ក៖  អូ៎!បាទលោកគ្រូ ចឹងមានន័យថាចូលឆ្នាំ1979ហើយណាពូ?

ខ៖  បាទចូលឆ្នាំ1979នឹង ប៉ុន្តែពេលណុងគ្រូអើយកន្លែងណាក៏មានឆ្អឹងខ្មោចដែរនឹង

ក៖  ដោយសារតែគេសំលាប់ច្រើនមែនទេពូ?

ខ៖  គេអូសទាំងរទេះៗនឹង ហើយសំរាប់ប្រជាជនចាស់នឹងក៏គេប្រាប់ខ្ញុំដែរនឹង
អ្នកខ្លះគេថាអូនអើយកុំទៅ ជាមួយគេ អ្នកខ្លះគេថាអូនអើយធ្វើការទៅ

ក៖  ចុះពូពេលណុងពូគិតយ៉ាងម៉េចដែរ?

ខ៖  ពេលណុងខ្ញុំធ្វើការកាប់ដី កាប់អីចេះតែធ្វើទៅនឹង ធ្វើជាទំនប់ទប់ ធ្វើជាអាងអីចឹងទៅណាស់លោកគ្រូ

ក៖  បាទពូធ្វើទាំងអស់ចឹងពូ?

ខ៖  នឹងធ្វើទាំងអស់នឹង
ហើយកាលពីជំនាន់ណុងអាពតវាកំនត់អោយធ្វើដីអោយបានកំពស់មួយម៉ែត្រ ចឹងហាសលោកគ្រូធ្វើមួយម៉ែត្របួនជ្រុងនឹង

ក៖  ប៉ុន្តែយើងចេះតែធ្វើទៅ?

ខ៖  ធ្វើបើមិនធ្វើម៉េចនឹងកើត គេកំនត់អោយធ្វើ2ម៉ែត្រគីប ព្រឹកមួយម៉ែត្រ យប់មួយម៉ែត្រដែរ

កៈ ចុះរបបអាហារវិញពូ?

ខៈ ប៉ុន្តែបបរគេចែកអោយតែម្នាក់មួយវែកៗបាយយើងនឹងទេ

កៈ មិនមែនបាយទេគឺបបរណាពូ?

ខៈ នឹងហើយបបរ ហើយគ្មានអីក្រៅពីសំឡក់ទេលោកគ្រូអើយ មានបន្លែ
មានស្ពៃចឹងទៅណាស់

កៈ ប៉ុន្តែរបបអាហារមនុស្សចាស់ នឹងមនុស្សក្មេងវាដូចតែគ្នាទេ?

ខៈ អាហារដូចគ្នាទេ ប៉ុន្តែមនុស្សចាស់បានផ្សេង មនុស្សចាស់បានប្រហែលជា2-3វែកក្រឡូមយើង

កៈ ចុះក្មេងវិញពូ?

ខៈ
នឹងសំរាប់មនុស្សចាស់ប៉ុន្តែសំរាប់មនុស្សក្មេងវាបានត្រឹមតែមួយវែកទៅពីរវែកទេអស់ហើយនឹង

កៈ អ៊ូ!គេគិតចឹងណាពូ?

ខៈ នឹងហើយមិនដូចថាឥឡូវយើងបានឆ្អែតៗទេ

កៈ បាទត្រូវហើយពូ

ខៈ កន្លែងខ្លះមិនដូចទៅភូមិចាផ្កាទេ គេបបរមួយខ្ទះត្នោតយើងនឹងអង្ករតែ2កំប៉ុងទេ

កៈ ចុះធ្វើម៉េចទៅម៉េចឆ្អែតទៅ?

ខៈ គេមិនដឹងទេបានតែមួយពីរកំប៉ុងទេនឹង

កៈ ចឹងយើងមានអង្ករណាហូបទៅពូ?

ខៈ នឹងហើយពេលដែរគេដុះមកបានតែអង្ករ2-3គ្រាប់នឹងនៅក្នុងចាននឹងនាំគ្នាហុតទៅ

កៈ ចុះពេលដែរចេញពីបាត់ដំបងគេអោយពូទៅណាទៀតទៅពូ?

ខៈ ចេញពីបាត់ដំបងនឹងនឹងវានៅទាល់តែវៀតណាមវៃចូលនឹងបានបែក

កៈ ដល់ពេលដែរបែកចឹងទៅបានពូចេញពីបាត់ដំបងមកវិញទៅ?

ខៈ នឹងបានចេញពីបាត់ដំបងនឹង

កៈ ប៉ុន្តែពេលដែរពូចេញពីបាត់ដំបងពូទៅណា មកស្វាយរៀងវិញរឺយ៉ាងម៉េចដែរពូ?

ខៈ ខ្ញុំត្រលប់មកស្វាយរៀងវិញនឹង
ដល់ពេលដែរមកនឹងក៏បានធ្វើដំណើរដើរមករហូតនឹងគ្រូ

កៈ ចុះដើររយៈពេលប៉ុន្មានខែដែរពូបានដើរមកដល់វិញនឹង?

ខៈ ដើរអស់រយៈពេលមួយខែដែរនឹង

កៈ ដើរអស់រយៈពេលមួយខែ ប៉ុន្តែយើងគ្នាច្រើនមែនទេពូ?

ខៈ បាទយើងដើរនឹងលក្ខណៈបន្តគ្នារហូតចឹងទៅ

កៈ ប៉ុន្តែនៅពេលដែរដើរនឹងក៏មានអ្នកស្លាប់អីដែរទៅ?

ខៈ មានតើ មានអ្នកស្លាប់ដែរនឹង អ្នកខ្លះមានធំក្បាលជង្គង់ទៅ

កៈ វាធំក្បាលធំក្បាលជង្គង់ម៉េចទៅពូ?

ខៈ មកពីក្បាលជង្គង់យើងធំគ្មានសាច់នឹង
គ្មានសាច់កំភួនជើងទេមានតិចៗនឹងហើយយើងធំក្បាលជង្គង់នឹង

កៈ ដោយសារតែយើងអត់មានអាហារណពូ?

ខៈ នឹងអត់មានអាហារនឹង

កៈ ហើយបានពូទៅស្វាយរៀង?

ខៈ បាទហើយបានដើរអស់រយៈពេលមួយខែនឹង
ហើយបានមានទាហ៊ានវៀតណាមមកដឹកទៅភ្នំពេញ

កៈ អូ៎!ចឹងហោសពូ?

ខៈ វាចឹងឯង

កៈ ចុះពេលដែរដាច់អាពតនឹងពូបានធ្វើអីគេខ្លះដែរទៀតទៅ?

ខ៖ ពេលដែររំដោះហើយនឹងខ្ញុំក៏មិនទាន់បានចំពេញវ័យប៉ុន្មានដែរទេនឹង គ្រាន់តែថាមកនៅភ្នំពេញនឹង កាលពីជំនាន់ណុងរកស៊ីដាក់អូស

ក៖ អ៎ូ!ពូរកស៊ីលក់អូសណោះពូ?

ខ៖ នឹងហើយវាចឹង

ក៖ ចឹងមានន័យថានៅជំនាន់ឆ្នាំ1980នឹងពូរកស៊ីលក់អូសនឹង?

ខ៖ នឹងហើយរកស៊ីលក់អីនឹង

ក៖ រហូតដល់ឆ្នាំ1983បានពូការ?

ខ៖ បាទដល់ពេលលក់អស់មួយឆ្នាំកន្លះបានឈប់លក់នឹង

ក៖ ចុះពេលដែរពូមានក្រុមគ្រួសារពូធ្វើអីគេដែរទៅ ពូមានជួបការលំបាកអីគេខ្លះទៅពេលដែរពូមាន ប្រពន្ធនឹងមានកូន?

ខ៖ លំបាកដែរគ្រូ

ក៖ លំបាកអីគេខ្លះដែរពូ?

ខ៖ មានការលំបាកដែរកាលណុងនៅសម័យរដ្ឋកម្ពុជា

ក៖ បាទចឹងនៅសម័យរដ្ឋកម្ពុជាណាពូ?

ខ៖ ពីព្រោះនោសម័យរដ្ឋកម្ពុជានឹងវាលំបាកលោកគ្រូ កាលជំនាន់ណុងម៉ែឪយើងពេលណុងមិនទាន់ មានអីគ្រប់គ្រាន់ផងនឹង

ក៖ វានៅខ្វះខាតមែនទេពូ?

ខ៖ កាលពីជំនាន់ណុងនៅខ្វះគោក្របី ខ្វះស្រូវពូជ នឹងខ្វះជីដាក់ស្រែ ខ្វះគ្រប់បែបគ្រប់យ៉ាងលោកគ្រូអើយ

ក៖ អ៎ូ!ចឹងហោសពូ?

ខ៖ ដល់ពេលចឹងទៅគាត់ចេះតែតស៊ូទៅណាស់ កាលជំនាន់ណុងដីស្រែសុទ្ធតែស្មៅ ហើយខ្ញុំចេះតែជួយ ត្រាយទៅអីចឹងទៅណាស់

កៈ ប៉ុន្តែពេលណុងពូធ្វើស្រែមែនទេពូ?

ខៈ បាទធ្វើស្រែនឹង ដល់ពេលហើយទៅខ្ញីពូជគេ រឺមួយក៏ពូជអង្គការគេចែកអោយចឹងទៅ នឹងសម័យរដ្ឋកម្ពុជានឹង គេចែកពូជអោយម្នាក់មួយតៅ រឺកន្លះតៅចឹងពូជស្រូវដើម្បីអោយធ្វើ

កៈ បាទត្រូវហើយពូ?

ខៈ ហើយដល់ពេលចឹងចេះតែធ្វើៗទៅចេះតែកើនៗឡើងចឹងទៅ ប៉ុន្តែធ្វើស្រែមួយជំនាន់ណុងគ្មានពូជ ធ្វើគ្រប់គ្នាទេ

កៈ ម៉េចចឹងទៅពូ?

ខៈ ចុះខ្វះខាតមិនចឹង ដូចថាមាននរណាម្នាក់មានក្របីទៅ ហើយយើងមានអីចឹងទៅបានផ្ដុំគ្នាទៅហើយ ក៏មកភ្ជួរទៅដូចថាយើងគ្មានក្របីគោទេ នឹងមានតែរកគេសំពះលើកដៃដាក់គេចឹងទៅ

កៈ អូ៎!សុំអោយគេជួយណាពូ?

ខៈ ទាល់តែយើងសំពះគេម្រាមដៃ10នឹង យើងសុំអោយគេជួយចឹងទៅហើយយើងជួយទៅដកស្ទូង អោយគេវិញទៅនឹងវាម្ដងម្នាក់ៗណាស់គ្រូ អោយវាផុតពីទុកលំបាក

កៈ នឹងហើយអោយផុតពីទុកបាកណាពូ?

ខៈ នឹងហើយ

កៈ ចុះពេលណាដែរពូគិតថាពូរៀងធូស្រាលជាងមុនចឹង នៅពេលដែរពូមានគ្រួសារចឹងដូចជាពេលណាដែរពូ?

ខៈ ពេលដែរយើងធូស្រាលនឹងទាល់តែយើងធ្វើស្រូវអង្ករបានខ្លះដែរនឹង ពេលបានស្រូវទៅយើងនឹង អាចលក់ស្រូវបានខ្លះទៅ នឹងលក់ក្របីបានមួយខាងអីខ្លះចឹងទៅ នឹងដូចថាធនធានយើងមិនទាន់បានក្រាស់ក្រែលចឹងគ្រូ

កៈ បាទត្រូវហើយនឹង

ខ៖ នឹងដូចថាយើងចិញ្ចឹមមាន់ ចិញ្ចឹមជ្រូកអីខ្លះទៅ
យើងអាចផ្សំនេះផ្សំនោះអីចឹងទៅណាស់ នឹងជាមួយក្របីចឹងទៅ
ដូចលក្ខណះថាមួយឆ្នាំបានមួយខាង រឺពីរឆ្នាំបានមួយខាងអីចឹងទៅណាស់

ក៖ បាទល្អដែរតើពូ?

ខ៖ បាទដល់ពេលចឹងចេះតែបន្តៗទៅនឹងដូចថាខ្ញុំទៅធ្វើស្រែបាន7-
8ឆ្នាំដែរពេលដែរខ្ញុំមិនបានទៅស្រុកវាចឹង

ក៖ ប៉ុន្តែពេលណុងពូមានកូនហើយរឺមួយក៏នៅទេ?

ខ៖ នៅមិនទាន់មានកូនទេគ្រូ មិនទាន់បានមានគ្រួសារទេខ្ញុំនៅតើ

ក៖ ដូចជាពូឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរពូ
ដូចជាធ្វើយ៉ាងម៉េចដើម្បីអោយផុតចឹង?

ខ៖ និយាយពីលំបាកនឹងមានច្រើនណាស់លោកគ្រូអោយ
វាមានតាមតង់វាដូចថាតាំងពីយើងនៅលីវនឹង រហូតមកដល់ចាស់

ក៖ អូ!មានរហូតនឹងហោសពូ?

ខ៖ ការលំបាកមានរហូតនឹងវាមិនបាត់ទេនឹង វាលក្ខណះតាមជាន់កែងយើងនឹង
វាតាមយើងរហូតទាល់តែដាច់សង្ខាយើងដាច់បានវាលែងតាមនឹង

ក៖ ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់ពូដែរ?

ខ៖ សប្បាយនៅពេលដែរយើងនៅកំលោះចឹងយើងសប្បាយហើយនឹង

ក៖ បាទត្រូវហើយពូ?

ខ៖ ដល់ពេលដែរយើងមានកូនចៅ រឺគ្រួសារយើងមិនសូវជាសប្បាយប៉ុន្មានដែរទេ
ទាល់តែកូនចៅបាន រៀបចំអោយចឹងទៅបានវាសប្បាយតិចចឹងទៅ

ក៖ បាទពូចឹងធ្វើអោយពូសប្បាយ?

ខ៖ នឹងហើយវាចឹង

ក៖ ចុះតាំងពីក្មេងពូធ្លាប់មានក្តីស្រម៉ៃថាពូធំឡើងចង់ធ្វើអីគេដែរទេ?

ខ៖ ពូកាលពីតូចធ្លាប់ក្តីស្រម៉ៃថាធ្វើជាគ្រូពេទ្យណាស់គ្រូ

ក៖ អូ៎!ពូចង់ធ្វើជាគ្រូពេទ្យណាពូ?

ខ៖ ប៉ុន្តែវាមិនបានដូចបំណង់ទេ

ក៖ ចឹងក្តីស្រម៉ៃរបស់ពូនឹងចង់ធ្វើពេទ្យ?

ខ៖ នឹងហើយចង់ធ្វើពេទ្យ

ក៖ ប៉ុន្តែពូមិនទាន់បានសម្រេចទេណាពូ?

ខ៖ ប៉ុន្តែវាមិនបានដុចបំណាងនឹង មិនបានដូចអ្វីដែរយើងប៉ង់ថប្រាថ្នាចឹង

ក៖ ចុះបើចង់អោយពូផ្តែផ្តាំទោកូនចៅជំនាន់ក្រោយៗតើពូចង់ផ្តែផ្តាំងីទៅពួកគាត់ដែរពូ?

ខ៖ ឥឡូវខ្ញុំគ្មានពាក្យអីចង់ផ្តែផ្តាំទេ មានតែសូមអោយបងប្អូនរួមជនជាតិខ្មែរទាំងអស់
ត្រូវគោរពតាមវប្បធ៌មរបស់ខ្មែរយើង ត្រូវចេះស្រលាញ់ខ្មែរយើង

ក៖ បាទត្រូវហើយពូ

ខ៖ ដើម្បីអនាគត់កូនចៅយើងតទៅមុខ កុំអោយវប្បធ៌មរបស់យើង
នឹងជាតិខ្មែររបស់យើងរលាយ នឹងបាត់បង់ចឹងណាស់លោកគ្រូ

ក៖ បាទពូត្រូវហើយនឹងពូ?

ខ៖ ដើម្បីយើងអាចទទួលស្គាល់សញ្ញាតិយើងអោយបានច្បាស់លាស់
កុំអោយឃើញជនជាតិយើងដែរ នឹងមិនមែនទេ ខ្ញុំសុំផ្តាំផ្ញើរប៉ុណ្ណឹង

ក៖ ចុះពូមានអីចង់ផ្តាំផ្ញើរអីផ្សេងទៀតទេពូ លក្ខណះថាចង់អោយកូនខ្មែរជៀសពីអីគេចឹង?

ខ៖ ប៉ុន្តែខ្ញុំចង់ផ្តាំផ្ញើរចេះ សុំអោយកូនខ្មែរទាំងអស់កុំអោយភ្លើតភ្លើននឹងគ្រឿងញៀន

ក៖ នឹងកុំអោយលួច ឆក់ប្លន់អីចឹងហោសពូ?

ខ៖ នឹងហើយលួច ឆក់ប្លន់អីនឹងគ្រប់បែបយ៉ាងអីកុំអោយសោះនឹង
យើងត្រូវរក្សាវប្បធ៌មរបស់យើងអោយបានត្រឹមត្រូវ សុំជាកូនខ្មែរ

កៈ ចឹងជាចុងក្រោយខ្ញុំអរគុណពូដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់ពូ
ហើយខ្ញុំនឹងដាក់សំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា
ហើយនឹងទុកការសំភាសន៍មួយនេះ អោយទៅពូវិញ
នឹងខ្ញុំចែកជាឌីសមួយដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិ
ឪពុកម្ដាយនឹងដូចតាចឹងហាសពូ

ខៈ បាទអរគុណលោកគ្រូ

កៈ បាទចឹងអរគុណច្រើនពូ៕៕៕